មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0072**

# សម្ភាសន៍ជាមួយឈ្មោះ ប្រាក់ និត ភេទស្រី អាយុ៥៤ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ពេទ្យកងពល៩២០

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើត នៅភូមិបារាយណ៍ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំថ្មដា ស្រុកកំរៀង ខេត្តបាត់ដឹបង

ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤៣:៤៦

សរុបៈ ២២ ទំព័រ

ដានី ៖ អ៊ីចឹងដឹបូងមីង ចង់ស្គាល់មីង មីងឈ្មោះអីគេ?

និតៈ ប្រាក់ និត ។

ដានី ៖ មីងអាយុប៉ុន្មានហើយ?

និតៈ ៥៤ ។

ដានី ៖ មីងសព្វថ្ងៃនៅភូមិអីដែរ?

និតៈ ភូមិស្វាយជ្រុំ ឃុំថ្មដា ស្រុកកំរៀង ខេត្តបាត់ដឹបូង

ដានី ៖ ស្រុកកំណើតមីងនៅណា?

និតៈ នៅបារាយណ៍ ។

ដានី ៖ ភូមិបារាយណ៍នេះ?

និតៈ ស្រុកបារាយណ៍ដែរ ។

ដានី ៖ កំពង់ធំ ។ ពូគាត់ឈ្មោះ កៅ សុន ត្រូវជាប្ដីរបស់មីង គាត់អ្នកនៅពកទំងន់ខាងស៊ឹងត្រង់ កំពង់ចាម?

និតៈ ចា៎!

ដានី ៖ មីងឪពុកមីងគាត់ឈ្មោះអីដែរ?

និតៈ គាត់ឈ្មោះ កន ។

ដានី ៖ អី កន ទៅ?

និតៈ ភ្លេចបាត់ហើយ ម៉ែខ្ញុំស្លាប់អស់ហើយ ។

ដានី ៖ ពុកស្លាប់ហើយ?

និត៖ ចា៎!

ដានី ៖ ស្លាប់តាំងពីកាល?

និត៖ តាំងពីខ្ញុំនៅតូច ។

ដានី ៖ ស្លាប់តាំងពីមីងនៅតូចៗ?

និត៖ ចា៎!

ដានី ៖ ម្ដាយ?

និត៖ ម្ដាយខ្ញុំឈ្មោះ យឹម ។

ដានី ៖ ឈ្មោះអី យឹម?

និត៖ អត់បានដឹងត្រកូលគាត់ទេ ខ្ញុំចូលមកតាំងពីតូច ក្មេច ។

ដានី ៖ ឈ្មោះ យឹម គាត់នៅរស់ទេ?

និត៖ ស្លាប់បាត់ហើយ ទើបតែស្លាប់បាន៣-៤ឆ្នាំ ។

ដានី ៖ ស្លាប់៣-៤ឆ្នាំនេះទេ ស្លាប់ដោយសារជំងឺ?

និត៖ ចា៎!

ដានី ៖ មីងបងប្អូនបង្កើតប៉ុន្មាននាក់?

និត៖ ឥលូវនៅ៤នាក់ ។ កាលមុន៥-៦នាក់ ដល់ចូលទ័ពបាត់ឈឹងអស់ទៅ បាត់អស់២នាក់ចូលទ័ព ។

ដានី ៖ អីចឹងទាំងអស់ ។

និត៖ ទាំងអស់៦នាក់ ។

ដានី ៖ ៦នាក់បងប្អូនបង្កើត?

និត៖ ចា៎!

ដានី ៖ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

និត៖ ស្រី២ ប្រុស៤ ។

ដានី ៖ អីចឹងមីងថានៅសល់ប៉ុន្មាន?

និត៖ សល់៤នាក់ បាត់កាលចូលទ័ព ឥលូវបាត់អត់ឃើញមកផ្ទះ ឃើញតែខ្ញុំមួយដែលចូលមក ចូល៣នាក់នៅតែខ្ញុំមួយទេ ។

ដានី ៖ តាំងពីមីងចូល បាត់តាំងពីឆ្នាំណា?

និត៖ ខ្ញុំចូលឆ្នាំ៧២ ។

ដានី ៖ ចុះបងប្អូន?

និត៖ បងប្អូនខ្ញុំចូលពីក្រោយ បែបឆ្នាំ៧៣-៧៤ ។

ដានី ៖ តាំងពីហ្នឹងបាត់មក?

និត៖ បាត់រហូត ។

ដានី ៖ ចូលខាងកងទ័ពរំដោះ?

និត៖ ចា៎!

ដានី ៖ ចុះមីងកូនទីប៉ុន្មាន?

និត៖ ខ្ញុំបងគេ បងខ្ញុំមួយស្លាប់ បងគេបង្អស់ដែលស្លាប់នៅកំពង់ចាម អាហ្នឹងចូលទ័ពដែល ដឹងតែស្លាប់ហើយមួយហ្នឹង អាមួយទៀតអត់ដឹងទេ ខ្ញុំទី២ ។

ដានី ៖ កាលពីក្មេងៗមីងបានរៀនសូត្រអីដល់ណា?

និត៖ ខ្ញុំអត់រៀនទេ រៀនសាលាវត្ត ។

ដានី ៖ មីងចេះអក្សរ?

និត៖ ចេះបានសរសេរ អានកើតដែរ ។ សរសេរអត់បានច្រើនទេ សរសេរបានតិច រៀនវត្តលោកកាលជំនាន់ហ្នឹងមានបានរៀនអី ។

ដានី ៖ រៀននៅវត្តនៅណា?

និត៖ វត្តបារាយណ៍ហ្នឹង រៀនជាមួយលោក ។

ដានី ៖ មីងរៀនបានប៉ុន្មានឆ្នាំបានឈប់?

និត៖ ខ្ញុំរៀនបាន២-៣ឆ្នាំ គេរើសយកទៅធ្វើរៀនពេទ្យប្រចាំភូមិ ពេទ្យស័គ្រចិត្ត ។

ដានី ៖ ពេទ្យស័គ្រចិត្ត ឆ្នាំណាហ្នឹង?

និត៖ ឆ្នាំ៧៣ ។

ដានី ៖ មីងគេជ្រើសរើសឲ្យចូលពេទ្យហ្នឹងឆ្នាំ៧៣?

និត៖ ចា៎! ហ្នឹងរៀនហើយមកបំរើក្នុងភូមិហ្នឹងដដែរ ។

ដានី ៖ រៀននៅណាទៅ?

និត៖ ទៅរៀននៅសំរោង ភូមិសំរោង ។

ដានី ៖ ភូមិសំរោងហ្នឹងនៅណាទៅ?

និត៖ នៅបារាយណ៍ហ្នឹងដែរ នៅជិតគ្នា ។

ដានី ៖ ឆ្នាំ៧៣ហ្នឹងគេជ្រើសរើសយ៉ាងម៉េច អ្នកណាមកជ្រើសរើស?

និត៖ អ្នកស្រុកភូមិហ្នឹង ប្រជាជនហ្នឹង សង្កាត់គេហ្នឹង គេរើសទៅឲ្យទៅរៀនពេទ្យមកបំរើប្រជាជនក្នុងភូមិហ្នឹង ខ្ញុំរៀនបំរើបានប៉ុន្មានទេ២ឆ្នាំ ខ្ញុំចូលទ័ពបណ្ដោយទៅ ។

ដានី ៖ ជ្រើសរើសទៅរៀនពេទ្យ រៀនបានរយៈពេលប៉ុន្មានទៅ?

និត៖ រៀនបានប្រហែលជិត៥ខែ ចេះល្មមៗគ្រាន់តែមកមើលបន្តិចៗ ។

ដានី ៖ រៀនពីអីខ្លះទៅ៥ខែហ្នឹង?

និត៖ រៀនពេទ្យព្យាបាលជំងឺគ្រុន រាគមួលស្អីៗហ្នឹងពេញតែគ្រប់ តែខ្ញុំមិនរៀនបានច្រើនណាមិនដូចពេទ្យគេសម័យនេះ ។

ដានី ៖ ពីណាអ្នកមកបង្រៀន?

និត៖ ភ្លេចឈ្មោះហើយ ភ្លេចរហូត ។

ដានី ៖ តែអ្នកក្នុងស្រុកភូមិហ្នឹងដែរអ្នកបង្រៀន ឬក៏អ្នក?

និត៖ អ្នកឆ្ងាយ អ្នកធ្វើចៅហ្វាយស្រុកគេចាត់តាំងកំលាំងមក មិនដឹងមកពីខាងណាបង្រៀនពួកខ្ញុំភ្លេចបាត់ទៅ ។

ដានី ៖ បង្រៀនច្រើនទេ? គ្នាដែរ?

និត៖ គ្នាច្រើនណាស់ចង់១០០នាក់ ប៉ុន្តែមួយស្រុក គេរើសម៉ាភូមិ១ៗ ។

ដានី ៖ ក្នុងស្រុកបារាយណ៍ហ្នឹង?

និត៖ ចា៎!

ដានី ៖ ភូមិ១ៗ?

និត៖ ចា៎!

ដានី ៖ ប្រធានគេអ្នករើស?

និត៖ ប្រធានសង្កាត់ ។

ដានី ៖ ឈ្មោះអីអ្នករើសហ្នឹង?

និត៖ ឈ្មោះ យើន ប៉ុន្តែស្លាប់បាត់ហើយឥលូវ បងខ្ញុំដឹងដូនមួយអ្នករើស ។

ដានី ៖ អីចឹងជាង១០០នាក់ សុទ្ធតែស្រីៗ ឬក៏មានប្រុស?

និត៖ សុទ្ធតែស្រី អត់មានប្រុស ។ តែកាលជំនាន់នោះគេមិនរើសអ្នកចេះទេ ច្រើនតែរើសអ្នកអត់សូវចេះអក្សរហ្នឹងទៅរៀន ។

ដានី ៖ ម៉េចអីចឹង?

និត: ចុះជំនាន់ខ្មែរក្រហម អ្នកចេះមិននេះប៉ុន្មាន ។

ដានី : កាលហ្នឹងមីងអាយុប៉ុន្មាន កាលទៅរៀនពេទ្យ?

និត: អាយុខ្ទង់ ១៥-១៦ ។

ដានី : រៀន៥ខែកាលហ្នឹង មីងចេះអីខ្លះ?

និត: ចេះតិចៗ ។

ដានី : ចេះអីគេ?

និត: ចេះឲ្យថ្នាំលេប ថ្នាំរាគ ថ្នាំគ្រុន តិចតួច ។

ដានី : កាលទៅរៀនគេបង្រៀនប្រាប់ថាម៉េច ជំងឺគ្រុន ជំងឺរាគ?

និត: គេប្រាប់ហ្នឹងយើងសរសេរមក តែខ្ញុំមកនៅពេទ្យព្យាបាលប្រជាជនហ្នឹងបានតែ១ឆ្នាំទេ ខ្ញុំចូលទ័ពខ្ញុំឈប់ហើយ ។

ដានី : មកពេទ្យព្យាបាលប្រជាជននៅណា?

និត: នៅភូមិហ្នឹងឯង ភូមិខ្ញុំ ។

ដានី : អ៊ីចឹងនៅក្នុងភូមិបាន១ឆ្នាំ?

និត: ចា៎! ខ្ញុំចូលទ័ពទៅ ។

ដានី : ម៉េចបានជាយើងព្យាបាលជំងឺប្រជាជនបានតែមួយឆ្នាំមក ចូលកងទ័ព?

និត: ខ្ញុំខ្ជិលនៅផ្ទះ នៅស្រុក ខ្ញុំចូលទ័ព កាលហ្នឹងខ្ញុំលំបាកនៅពេក ខ្ជិល ។

ដានី : ម៉េចបានលំបាក?

និត: កាលហ្នឹងម៉ែខ្ញុំគេ ឲ្យម៉ែខ្ញុំយកប្ដី ទៅខ្ញុំនឹកឃើញខ្មាស់គេធំហើយ ខ្ញុំខឹង ខ្ញុំចូលទ័ពទៅ ។ កាលហ្នឹងគាត់មិនចង់បានទេ តែគណៈស្រុកឲ្យគាត់ផ្គូរផ្គងឲ្យយកអ្នកធ្វើការជាមួយ ខ្ញុំនឹកក្នុងចិត្តខ្មាស់គេចូលទ័ពបាត់ទៅ ។

ដានី : កាលហ្នឹងម្ដាយមីងគាត់យកប្ដីថ្មីទៀត?

និត: ចា៎! តាំងពីហ្នឹងខ្ញុំចូលរហូត ខ្ញុំលែងទៅផ្ទះទៅ ដល់ផ្ដាច់ខ្លួនបានខ្ញុំចូល ។

ដានី : អ៊ីចឹងមីងចូលទ័ពឆ្នាំណា?

និត: ក្នុងឆ្នាំ៧៣-៧៤ហ្នឹងឯង ចូលមកនៅស្រុក អីណាបាក់ស្នា ក្រវ៉ា ។

ដានី : បាក់ស្នា ក្រវ៉ា នៅខាងលើភ្នំនេះវិញហើយ?

និត: ចា៎! ទៅនៅក្រវ៉ា បាក់ស្នា ទៅលើកទំនប់បានប្រហែល២-៣ខែ គេបញ្ជូនមកភ្នំពេញតែម្ដង ។

ដានី : កាលហ្នឹងម្ដាយមីងធ្វើអីដែរ បានគេរៀបចំផ្ដុំឲ្យគាត់មានគ្រួសារថ្មី?

និតៈ មិនដឹងធ្វើអីក្នុងភូមិហ្នឹង ខ្ញុំមកបាត់មក វាមិនដឹង ធ្វើជាមួយពូ ឈៅ ដែលសម្ភាសន៍មិញ ដឹងស្គាល់ម៉ែខ្ញុំ ប៉ុន្តែគាត់នៅស្រុកឆ្ងាយតែគាត់ទទួលនៅហ្នឹង គាត់ស្គាល់ម៉ែខ្ញុំដែរ ពូដែលមកមិញហ្នឹង ការងារជាមួយម៉ែខ្ញុំ តែដល់ពេលខ្ញុំខឹងខ្ញុំមិនដឹងគាត់ធ្វើការអី ខ្ញុំទៅបាត់ លែងមកផ្ទះវិញមក ទើបតែផ្ដាច់ខ្លួនហ្នឹងទេ ។

ដានី : ចុះម្ដាយមីងគាត់មានគ្រួសារថ្មី គាត់មានកូនទៀតដែរ?

និតៈ អត់ទេ ។

ដានី : នៅរហូតដល់គាត់ចាស់ៗនៅជាមួយគ្នា?

និតៈ អត់ទេ គាត់ស្លាប់ដែរ ឪពុកខ្ញុំក្រោយគាត់ស្លាប់ដែរ កាលម៉ែខ្ញុំទើបតែស្លាប់ ។

ដានី : ឪពុកក្រោយមីងគាត់ធ្វើអីដែរ?

និតៈ ខ្ញុំអត់ដឹងទេ ។

ដានី : អ៊ីចឹងដល់ពេលមីងខឹង មីងទៅស្ម័គ្រចិត្តចូលតែម្ដង?

និតៈ ចា៎!

ដានី : កាលហ្នឹងមីងចូលតែម្នាក់ឯង ឬមានអ្នកផ្សេងចូលជាមួយដែរ?

និតៈ ខ្ញុំទៅតែឯង ពួកអាក្នុងរាំសិល្បៈក្នុងភូមិហ្នឹងគេអត់ទៅទេ ខ្ញុំទៅតែឯង ។

ដានី : មានសិល្បៈដែលកាលហ្នឹងក្នុងភូមិ?

និតៈ ចា៎! នៅក្នុងភូមិហ្នឹងមាន ពេទ្យធំ នៅរាំសិល្បៈគេហ្នឹងដង ។

ដានី : ពីណារៀបចំឲ្យមានរាំសិល្បៈ?

និតៈ សង្កាត់គេហ្នឹង សង្កាត់ យើង ។

ដានី : គណៈស្រុកកាលហ្នឹងឈ្មោះអីគេ?

និតៈ ខ្ញុំអត់ស្គាល់ទេ កាលហ្នឹងស្រី គណៈស្រុកកាលហ្នឹង ខ្ញុំមក មកបាត់តែម្ដងទៅ ដល់ដាច់ ៧៥ខ្ញុំទៅនៅមណ្ឌលគិរីបានចូលពេទ្យកងទ័ព ។

ដានី : អ៊ីចឹងពេលមីងចេញពីហ្នឹងមក មីងទៅនៅខាងក្រវ៉ា នៅខាងបាក់ស្នា ធ្វើអីទៅ?

និតៈ ធ្វើទ័ព កាលហ្នឹងដល់ទៅនៅលើកទំនប់សិន ដល់លើកទំនប់ហើយ គេបញ្ជូនខ្ញុំមកនៅទំនប់ជើងព្រៃនេះ ។

ដានី : ហៅទំនប់អីគេហ្នឹង?

និតៈ កន្លែងដើងព្រៃហ្នឹងមិនដឹងទំនប់ស្អីគេទេ នៅត្រង់ហ្នឹង ហូបបាយមួយរយៈ ហើយបានគេបញ្ជូនមកនៅភ្នំពេញ ។

ដានី ៖ កាលនៅបាក់ស្នា នៅក្រវ៉ាហ្នឹង នៅលើកទំនប់ហ្នឹង នៅអង្គភាពអីគេ?

និតៈ មិនដឹងអង្គភាពអីទេ ខ្ញុំមិនបានសួរនាំអីគេទេ ។

ដានី ៖ កងទ័ព ឬនៅខាងកងចល័ត?

និតៈ មិនដឹងកងចល័ត កងអី តែនៅលើកទំនប់ គេឲ្យនៅបានតែប៉ុន្មានខែ គេបញ្ជូនមកត្រៀមស្អែងវ៉ៃ៧៥នេះ ។

ដានី ៖ មកនៅធ្វើកងស្អែង?

និតៈ ចា៎!

ដានី ៖ កងស្អែងត្រៀមសែងពួកកងទ័ពត្រូវរបួស?

និតៈ ចា៎! ឲ្យសែងស្អែង ។

ដានី ៖ សែងស្អែងពីណាទៅណា?

និតៈ មុំស្ពានស៊ីត្តា កន្លែងឪខ្ញុំនៅ កងពលជាមួយគ្នា ។

ដានី ៖ មីងនៅក្នុងកងពលដែរ កាលហ្នឹងយើងនៅកងស្អែង យើងនៅក្នុងកងពលដែរ?

និតៈ កងពល៩២០ កងពលទី២ ។

ដានី ៖ មីងនៅជាមួយកងពីណាគេ?

និតៈ ខ្ញុំនៅជាមួយ យាយថាត តែគាត់ស្លាប់បាត់ហើយ ។

ដានី ៖ យាយថាត ហ្នឹងគាត់ខាងអី គេហៅកង?

និតៈ កងវរៈ ។

ដានី ៖ សុទ្ធតែនារីៗ?

និតៈ សុទ្ធនារី ។

ដានី ៖ គាត់អ្នកគ្រប់គ្រងនារី?

និតៈ ចា៎! គេបញ្ជូនទៅមណ្ឌលគិរីគាត់ស្លាប់បាត់ទៅ ។

ដានី ៖ អីចឹងកាលហ្នឹងមីងនៅកងស្អែងហ្នឹងរហូតដល់បែកភ្នំពេញ?

និតៈ ចា៎! នៅកងស្អែងរហូតដល់ដាច់ភ្នំពេញ បានគេបញ្ជូនខ្ញុំទៅមណ្ឌលគិរី ។

ដានី ៖ កាលនៅកងស្អែងសែងអ្នករបួសពីកន្លែងណា ទៅកន្លែងណាទៅ?

និតៈ សែងគេដាក់១គីឡូមួយក្រុមៗ សែងពី១ក្រុមនោះទៅដាក់១ក្រុមនេះ បន្តគ្នារហូតដល់មន្ទីរពេទ្យ ។

ដានី : មន្ទីរពេទ្យនៅណា?

និតៈ នៅណាទេ ខ្ញុំមិនស្គាល់ទេ ខត្តុក្កក្រុងកំពង់ហ្លួងគេ ។

ដានី : ខាងខត្តុក្ក កំពង់ឆ្នាំង អមលាំង?

និតៈ ចា៎! ខ្ញុំនៅមួយជីនាខាងហ្នឹង ខត្តុក្ក ភ្នំប្រសិទ្ធ ខ្ញុំនៅកន្លែងទល់ផ្លូវភ្នំប្រសិទ្ធ ខ្ញុំនៅត្រៀមហ្នឹង ។

ដានី : កាលហ្នឹងយើងនៅក្មេងៗ ស្រីៗ អីចឹង ហើយអ្នករបួសសុទ្ធតែកងទ័ព ប្រុសៗ ហើយធ្ងន់អីចឹង យើងសែងម៉េចរួចទៅ?

និតៈ អត់ហ៊ានទំលាក់ទេ ខ្លាចគេធ្វើបាប ។

ដានី : យើងសែងម៉េចទៅ គ្នាប៉ុន្មាននាក់?

និតៈ គ្នា២នាក់សែងមុខក្រោយ មានផ្លាស់គ្នា៤នាក់ បើថានេះមាន២នាក់អមខាង ដល់ពេលយើងធ្ងន់យើងដូរទេ ។

ដានី : ធ្ងន់កាលហ្នឹង?

និតៈ ជួនកាលរបួសអត់ស្លាប់អីគេដាក់២នោះ ។

ដានី : ដាក់២ទៀត?

និតៈ ចា៎!

ដានី : សែងតាមម៉េច សែងតាមអង្រឹង ឬសែង?

និតៈ សែងអង្រឹង ដាក់អង្រឹងសែង ធ្ងន់យើងបេះតែសែងទៅ ទៅដល់ដំបូងខ្លាចខ្មោចណាស់ អត់ហ៊ានចុះសែង ប៉ុន្តែគេគំរាម ។

ដានី : អ្នកស្លាប់គេឲ្យសែងដែលអត់?

និតៈ ចា៎! បើមិនសែងម៉េច ដល់កន្លែងយើង យើងសែង ។

ដានី : ធ្ងន់ៗទេដល់ពេលសែង?

និតៈ ធ្ងន់ ពួកខ្ញុំនៅតូចៗ មានធំប៉ុន្មាន អាយុ១៦-១៧ ចង់សែងអត់ផុតភ្លឺស្រែផង អូសហើយសែងបណ្តើរជួនកាលយន្តហោះទំលាក់គ្រាប់បែកយើងក្រាបនៅហ្នឹង ។

ដានី : សែងរាល់ថ្ងៃម៉េចកាលហ្នឹង?

និតៈ សែងរាល់ថ្ងៃ យប់ភ្លឺៗ យប់ថ្ងៃ ល្ងាចដេកបាន១ភ្លិបៗទេ ទំរាំរើម៉ាដាច់ភ្នំពេញហ្នឹង ។

ដានី ៈ ១ថ្ងៃៗប្រហែលប៉ុន្មានទៅ តាមមីងសែង?

និតៈ ស្នែងរបួសក្រែលដែលហ្នឹង ដូនកាលវា បើថ្ងៃណាវាមួយៗដែល តាមគេវៃខ្លាំង វៃតិចៗ។

ដានី ៈ តែយើងសែងទៅខាងកំពង់ស្ពឺ ខាងខត្តុង្គ?

និតៈ ខាងហ្នឹងឯងខ្ញុំកងពលទី២នោះ សែងទៅមន្ទីរពេទ្យ។

ដានី ៈ កាលហ្នឹងមីងស្គាល់ពូដែរ?

និតៈ អត់ទេ។

ដានី ៈ អត់ទាន់ស្គាល់គ្នាទេ?

និតៈ ចា៎! ទៅនៅមណ្ឌលគិរីបានស្គាល់។

ដានី ៈ កាលហ្នឹងមីងអត់ទាន់បានទៅធ្វើពេទ្យទេ នៅតែសែងរបួសរហូត?

និតៈ ចា៎! នៅសែងរបួសរហូតទាល់តែដាច់ភ្នំពេញ បានខ្ញុំចុះទៅមណ្ឌលគិរី ទៅដល់ក្រចេះគេជ្រើសរើស គេធ្វើប្រវត្តិរូបទៅគេឃើញខ្ញុំធ្វើពេទ្យកាលពីសម័យខ្ញុំនៅភូមិ គេបញ្ចូលទៅពេទ្យកងពលទៅ។

ដានី ៈ មីងដូចថាកាលមីងនៅក្នុងកងវរៈ ឈ្មោះ ថាន គាត់ប្រធានកងវរៈសេនាតូច ឬសេនាធំ?

និតៈ វរៈសេនាធំ។

ដានី ៈ មីងកាលហ្នឹងនៅជាយុទ្ធជន ឬមានតួនាទីអី?

និតៈ អត់។

ដានី ៈ ពេលបែកភ្នំពេញឆ្នាំ៧៥ហើយ យ៉ាងម៉េច នៅណា?

និតៈ ទៅនៅមណ្ឌលគិរី។

ដានី ៈ ពេលបែកហើយមីងចូលទៅភ្នំពេញដែរ?

និតៈ ចា៎!

ដានី ៈ ពេលបែក៧៥ ពេលយើងវៃភ្នំពេញបាន?

និតៈ ខ្ញុំទៅនៅភ្នំពេញ។

ដានី ៈ នៅម្តុំណា?

និតៈ នៅម្តុំទួលគោក។

ដានី ៈ ធ្វើអីទៅ?

និតៈ ខ្ញុំនៅក្មេងៗអត់ដឹងអីទេ ដើរតែពេញដី ដើរតែពេញភ្នំពេញ។

ដានី ៖ គេឲ្យយើងរៀបចំឥវ៉ាន់?

និតៈ ឲ្យប្រមូលឥវ៉ាន់តាមផ្ទះ ប៉ុន្តែខ្ញុំគេអត់សូវប្រើទេ វានៅតូចជាងគេ ដើរតែតាពាតាពាស ។

ដានី ៖ មីងមានបានរើសបានរបស់របរណាមានតំលៃអី?

និតៈ អត់ហ៊ានយក ទៅទំលាក់ក្នុងអណ្តូង បើខ្ញុំទៅដល់មណ្ឌលគិរីខ្ញុំបានមាស១ខ្សែដែរ ដល់គេស្រាវជ្រាវខ្ញុំយកទៅទំលាក់ចោលក្នុងអណ្តូងបាត់ទៅ ។

ដានី ៖ អណ្តូងនៅណាទៅ?

និតៈ អណ្តូងក្រចេះតែមិនដឹងត្រង់ណា ត្រង់ណី ។

ដានី ៖ មីងអត់ទៅរកវិញ?

និតៈ អត់ទៅទេ ។

ដានី ៖ មីងអត់ចាំអណ្តូងហ្នឹងទេ?

និតៈ នៅផ្សារក្រចេះ ខ្ញុំនៅកន្លែងផ្សារក្រចេះនៅជាក់មន្ទីរពេទ្យ ។

ដានី ៖ កាលហ្នឹងមីងបានខ្សែកហ្នឹងពីណា?

និតៈ នៅតាមផ្ទះនៅភ្នំពេញ អត់ហ៊ានយកទេខ្លាច យកហ្នឹងលាក់ទេ ។

ដានី ៖ ម៉េចបានមីងទៅទំលាក់ចោលក្នុងអណ្តូង?

និតៈ ខ្លាចគេចាប់ ។

ដានី ៖ គេប្រកាស?

និតៈ គេស្រាវជ្រាវ កាលណាយកស្អីចេញពីភ្នំពេញអត់បានទេ ។

ដានី ៖ មីងមានតែមួយខ្សែហ្នឹងទេ ចុះពូ?

និតៈ ឪខ្ញុំនៅជាមួយកងវរៈ គាត់និយាយ គាត់ថាមាសគេដាក់ប្រឡាក់ម្រាក់នោះ ដាក់នៅលើជើងពាន គាត់យកបោះលេង កងវរៈគេយកទៅ អត់ហ៊ានទេ ជំនាន់ហ្នឹង អត់ហ៊ានយកទេស្អីក៏ដោយ សូម្បីតែនាឡិការក៏អត់ហ៊ានដែរ ខ្លាចគេចាប់ ។

ដានី ៖ មីងយកបាន១ខ្សែហ្នឹងធំទេ ខ្សែហ្នឹង?

និតៈ ធំដែរ តែខ្ញុំទំលាក់ក្នុងអណ្តូង ។

ដានី ៖ ប៉ុន្មាន?

និតៈ ចង់១ជីឡូង ។

ដានី ៖ យកទៅទំលាក់ក្នុងអណ្តូង មីងអត់ចាំអណ្តូងហ្នឹងទេ? អត់ចង់ទៅរកវិញទេ?

និតៈ អត់ទេ ។

ដានី ៖ ម៉េចអីចឹង?

និតៈ ខ្លាច ដូចគេថា អ្នកកប់កំណប់ហើយគេទៅរកកន្លែងវិញ ដល់គេដឹងថាកំណប់គេប្តឹងប៉ូលីស ថាយើងចង់គាស់កកាយស្អីគេ ខ្ញុំលឺគេនិយាយគគោក ។

ដានី ៖ មិនស្នាក់នៅភ្នំពេញបានរយៈពេលប៉ុន្មានទៅ?

និតៈ ដូចគាត់ដែរ ខ្ញុំចូលទៅជាមួយគ្នា ខ្ញុំបញ្ជូនទៅមុនគាត់ ខ្ញុំទៅក្រចេះមុនគាត់ ខ្ញុំពេទ្យកងពលទៅប្រចាំនៅហ្នឹងមុន ។

ដានី ៖ ទៅមុនគាត់ ទៅក្រចេះមុន?

និតៈ ប៉ុន្តែខ្ញុំមិនដែលស្គាល់គាត់ទេ?

ដានី ៖ កាលហ្នឹងមីងទៅដល់ក្រចេះ មីងរៀបចំយ៉ាងម៉េចទៅ? រៀបចំថ្មីអីយ៉ាងម៉េច? មីងចាប់ផ្តើមធ្វើអី?

និតៈ ខ្ញុំធ្វើពេទ្យហ្នឹងឯង អត់មានរៀបចំអីទេ ប៉ុន្តែបានពេទ្យ ពូជូៗ គេទើបតែបញ្ជូនទៅ ពីភូមិភាគពិសេសគាត់ប្រធានបច្ចេកទេសតែម្តង អ្នកព្យាបាល វះកាត់អី ជំងឺទូទៅអីទាំងអស់មីងវីន គាត់គ្រាន់តែគ្រប់គ្រងពីលើគេ គាត់អត់មានចេះអីទេ ។

ដានី ៖ មីងវីន គាត់អត់ចេះអីទេ?

និតៈ ចាំ!

ដានី ៖ ចាំមើលឆ្នាំ៧៥ ពេលបែកភ្នំពេញហើយ មីងគេផ្តើមរៀបចំអីយ៉ាងម៉េច? មីងអាចចាំទេ?

និតៈ កាលហ្នឹងខ្ញុំនៅវគ្គយាយថាន ហ្នឹង ដំបូងគេប្រុងឲ្យខ្ញុំទៅខេត្តស្ទឹង សមុទ្រ ហើយមិនដឹងម៉េចបានគេតវ៉ា បានគេបញ្ជូនខ្ញុំមកមណ្ឌលគិរី បញ្ជូនមកដល់ក្រចេះគេស្រាវជ្រាវរើសយកខ្ញុំហ្នឹងធ្វើពេទ្យកងពលបណ្តោយ ខ្ញុំដាច់ពីវរៈ យាយថាន ហ្នឹងហើយ នៅពេទ្យហ្នឹងតែម្តង នៅពេទ្យប្រហែលយូរដែរ ទំរាំទ័ពឡើងទៅមណ្ឌលគិរីអស់ បានគេបញ្ជូនខ្ញុំទៅកោះញែក ទៅប្រចាំនៅកោះញែក មន្ទីរពេទ្យកោះញែក ។

ដានី ៖ ចាំមើលពីភ្នំពេញដំបូងគេឲ្យមីងទៅខាងណា? ទៅខាង?

និតៈ ទៅកំពង់សោម ។

ដានី ៖ មីងទៅកំពង់សោមបានរយៈពេលប៉ុន្មាន?

និតៈ អត់ទៅទេ ដល់ក្រោយមកគេប្រែវិញ គេអត់ឲ្យទៅ គេឲ្យទៅមណ្ឌលគិរីវិញ ។

ដានី ៖ ខែប៉ុន្មាន មីងចាំខែទេ?

និត: មិនដឹងខែប៉ុន្មានទេ ចេញពីភ្នំពេញ ។

ដានី : ក្នុងឆ្នាំ៧៥ ហ្នឹងដែរ ។

និត: ចា៎! ក្នុងហ្នឹងឯង ។

ដានី : កាលហ្នឹងគេអត់ទាន់រៀបចំជាពេទ្យនៅឡើយទេ?

និត: នៅទេ ទៅដល់ក្រចេះបានគេរៀបចំ ។

ដានី : ទៅដល់ក្រចេះគេរៀបចំធ្វើពេទ្យយ៉ាងម៉េចទៅ?

និត: គេជ្រើសរើសធ្វើប្រវត្តិរូបហើយ ឲ្យយើងសរសេរក្នុងប្រវត្តិរូបហើយ គេឃើញយើងដាក់ពេទ្យគេជ្រើសយើងយកទៅពេទ្យ ខ្ញុំលែងនៅវរៈ យាយថាន ទៀតហើយ ។

ដានី : លែងនៅវរៈ យាយថាន ទៀតហើយ?

និត: ខ្ញុំទៅពេទ្យកងពលម្ដង ។

ដានី : ពេទ្យកងពលណា?

និត: កងពល៩២០ ។

ដានី : ពេទ្យរបស់កងពល?

និត: ចា៎!

ដានី : ពេទ្យគ្នាច្រើនទេ?

និត: ច្រើន មួយពេទ្យហ្នឹងក្បែរ ៥០-៦០ ជិត១០០នាក់ គ្រាន់តែទៅប្រចាំមុខខ្លះ ។

ដានី : អីចឹងពេទ្យហ្នឹងគេរៀបចំថ្មី មិនមែនចាស់ពីជំនាន់មីងសែងស្នែងទេ?

និត: អត់ទេ ។

ដានី : រៀបចំថ្មី?

និត: ចា៎! តែមិនដឹងជាពេទ្យថ្មី ពេទ្យចាស់ ប៉ុន្តែគេយកខ្ញុំទៅបញ្ចូលក្នុងពេទ្យហ្នឹងតែម្ដង ។

ដានី : គេបញ្ចូល ប្រធានពេទ្យឈ្មោះ មីងវីន?

និត: មិនមែន មីងវីន ទេ ហ្នឹងពេទ្យប្រធានឈ្មោះស្អីទេ ខ្ញុំភ្លេចបាត់ហើយនៅនឹងក្រចេះហើយ គេយកពេទ្យពីភូមិភាគពិសេសនេះទៅ ដូយកពីភូមិភាគពិសេសទៅនៅហ្នឹងធ្វើប្រធាន បច្ចេកទេស ខ្ញុំឃើញតែ ពូដូ ហ្នឹងឯងខ្ញុំអត់ដឹងពេទ្យពីខាងណាមក អត់ដឹងទេ ។

ដានី : ដល់ពេលហ្នឹង មីងនៅក្រចេះគេរៀបចំជាពេទ្យ គេឲ្យយើងរៀនសូត្រអីយ៉ាងម៉េច?

និតៈ	ព្យាបាលជំងឺតែម្តង អត់ទាន់បានរៀន រៀនដាក់ស្តែងតែម្តង គេសរសេរសារបានឲ្យយើង ថ្នាំអីៗត្រូវចាក់អីយើងមើលតាមសារបានគេហ្នឹង ចាក់ ។

ដានី :	អីចឹងពេលដែលដល់ក្រចេះយើងអត់រៀនទៀតទេ យើងទៅព្យាបាលជំងឺ?

និតៈ	ចា៎!

ដានី :	ព្យាបាលជំងឺនៅណា?

និតៈ	នៅមន្ទីរពេទ្យហ្នឹងក្រចេះហ្នឹង គេដាក់មន្ទីរពេទ្យក្រចេះហ្នឹងតែម្តង ពេលដែលគាត់ពិនិត្យ ហើយគាត់សរសេរសារបានឲ្យយើង ។

ដានី :	ឈ្មោះអី ពូជូ ហ្នឹងអ្នកពិនិត្យ?

និតៈ	ចា៎! ពូជូ អ្នកពិនិត្យ ហើយយើងចាក់តាមគាត់ យើងយកសារបានទៅឃ្លាំងគេបើកមក ។

ដានី :	យូរអត់មីងព្យាបាលនៅហ្នឹង?

និតៈ	យូរខ្ញុំនៅយូរដែរ ១ឆ្នាំ ហើយទ័ពគេឡើងទៅអស់ បានគេបញ្ជូនខ្ញុំទៅ ។

ដានី :	កាលមីងនៅព្យាបាល ដូចថាមីងបានចេះច្រើន មីងបានចាក់ថ្នាំ យើងបានព្យាបាលអ្នកជំងឺ ដោយផ្ទាល់ដៃខ្លួនឯងបានច្រើនទេ?

និតៈ	បាន គេអត់ឲ្យខ្ញុំទៅដាំបាយអីទេ គេឲ្យតែខ្ញុំព្យាបាល ។

ដានី :	ព្យាបាលជំងឺអីខ្លះទៅកាលហ្នឹង?

និតៈ	ជំងឺគ្រុនចាញ់ របួស ភាគច្រើនគ្រុនចាញ់ទៅដល់ដំបូង សន្លប់បាត់មាត់រាប់ខែ ដាក់សារ៉ូម បោលឡើងដំបៅអស់គូទអី ដំបៅព្យាបាលខ្លះជាទៅ ខ្លះក៏អត់ជាស្លាប់ ប៉ុន្តែខ្ញុំគេច្រើនតែ ដាក់កន្លែងអ្នកជំងឺធ្ងន់ អ្នកសន្លប់តែម្តង ខ្ញុំអត់សូវចេះអីច្រើន អ្នកខ្លះគេខ្ទើមគេអត់សូវដឹង

ដានី :	ព្យាបាលដូចជំងឺគ្រុនចាញ់ឲ្យថ្នាំអីទៅ?

និតៈ	កាលជំនាន់នោះថ្នាំចិនផង ហើយថ្នាំយើងស្លូ ។

ដានី :	ថ្នាំចិន ថ្នាំអីទៅ?

និតៈ	ថ្នាំគីនីន កាលជំនាន់ហ្នឹង ហើយគេច្រើនតែស្លូថ្នាំដាក់ដប អាហ្នឹងគីនីនដែរតែគេស្លូ ។

ដានី :	គេឲ្យថ្នាំហ្នឹង?

និតៈ	ចា៎! គេចាក់ ហើយគេប្រើវីតាមីន បើជាទៅគេប្រើវីតាមីន ហើយគេដាក់សារ៉ូម ។

ដានី :	ភាគច្រើនជាទេអ្នកជំងឺ?

និតៈ	ជា តែអ្នកខ្លះវាដូចថាយកមកជ្រុលហួសហើយ ជួយមិនបានទេ អ្នកខ្លះដឹកមកស្លាប់លើ ឡាន ស្លាប់ច្រើនអ្នកឡើងទៅភ្នំ ។

ដានី ៖ ព្យាបាលនៅក្រចេះហ្នឹងរយៈពេលប៉ុន្មាន បានគេបញ្ជូនមីងទៅមណ្ឌលគិរី ទៅកោះញែក?

និតៈ ១ឆ្នាំ ។

ដានី ៖ ដល់ខែប៉ុន្មាន ឆ្នាំប៉ុន្មាន បានមីងទៅកោះញែក?

និតៈ កាលហ្នឹង៧៥-៧៦ ចូល៧៦ ។

ដានី ៖ កាលហ្នឹងទៅគ្នាច្រើនទេ ទៅកោះញែក?

និតៈ ទៅទាំងអស់ ដឹកពេទ្យកងពលទៅតែម្តង ។

ដានី ៖ ពេទ្យកងពលប៉ុន្មាននាក់?

និតៈ ចង់ប្រហែល៥០-៦០ ជិតមួយរយនាក់ តែដឹកទាំងរបួសទាំងអីទៅទាំងអស់ អ្នកជំងឺអី ។

ដានី ៖ ថាឈ្មោះ ពូជូ ហ្នឹងទៅដែរ?

និតៈ ចា៎!

ដានី ៖ កាលហ្នឹងពេទ្យមានស្រី មានប្រុស?

និតៈ មានស្រី ប្រុស មានទាំងអស់ ។

ដានី ៖ ជូ ហ្នឹងគាត់ធ្វើប្រធានពេទ្យ?

និតៈ ចា៎! ប្រធានបច្ចេកទេស ។

ដានី ៖ ចុះប្រធានធំ?

និតៈ មីងវីន ហ្នឹងហើយ គាត់គ្រប់គ្រង ។

ដានី ៖ គាត់គ្រប់គ្រងតាំងពីក្រចេះទៅ?

និតៈ ចា៎! មីងវីន គ្រប់គ្រងទៅដល់មណ្ឌលគិរីទេ ជូ ហ្នឹងគាត់នៅក្រចេះ មីងវីន ទៅដល់មណ្ឌលគិរីបានគាត់គ្រប់គ្រង មាន៣ មានមីងវីន មានយាយអីទេ គាត់អត់មានចេះបច្ចេកទេសអីទេ ហើយ បងសៀន បច្ចេកទេសគាត់នៅភ្នំពេញហើយឥលូវ ។

ដានី ៖ ឈ្មោះអី សៀន?

និតៈ ចា៎! បងសៀន ហ្នឹងបន្ទាប់ពី ពូជូ មក បងសៀន ។

ដានី ៖ ឥលូវគាត់នៅរស់ដែរ?

និតៈ ចា៎! នៅភ្នំពេញ ។

ដានី ៖ គាត់នៅភ្នំពេញនៅណាទៅ?

និតៈ មិនដឹងទៅនៅត្រង់ណាទេ គាត់ចេញពីត្រង់នេះហើយទៅនៅភ្នំពេញ គាត់ចិត្ត ។

ដានី ៖ គាត់ទៅនៅយូរហើយ?

និតៈ ទៅនៅយូរដែរហើយ ដល់សែនគាត់ខស្សាហ៍មកនេះវិញដែរ គាត់ស្គួតណាស់ ។

ដានី ៖ មីងវីន គាត់ទៅគ្រប់គ្រងឆ្នាំណា?

និតៈ ទាល់តែខ្ញុំទៅនៅមណ្ឌលគិរីជិតកន្លះឆ្នាំ បានគាត់ទៅគ្រប់គ្រង មិនដឹងឆ្នាំណាខ្ញុំមិនដឹងដែរ ។

ដានី ៖ ៧៦-៧៧?

និតៈ ខ្ទង់៧៦ ចុង៧៦ ដើម៧៧ហ្នឹងគាត់ទៅ ។

ដានី ៖ កាលហ្នឹងគាត់មានគ្រួសារនៅ ពេលគាត់ទៅ?

និតៈ មានតើ បងសាន មានកូនហើយ ។

ដានី ៖ ប៉ុន្តែ សាន ហ្នឹងគាត់ទៅមុន ឬម៉េច?

និតៈ បង០៦ ទៅមុន ។

ដានី ៖ ០៦ ទៅមុន ហើយបានគាត់ទៅក្រោយ?

និតៈ បាន មីងវីន ទៅក្រោយ ។

ដានី ៖ វីន ឈ្មោះគាត់ពេញឈ្មោះអី វីន?

និតៈ ខ្ញុំអត់ដឹងត្រកូលគាត់ទេ ខ្ញុំហៅតែ មីងវីនៗ ។

ដានី ៖ គាត់ចំណាស់ណា បានមីងហើយមីង?

និតៈ គាត់ចាស់ហើយហ្នឹង ឥលូវហ្នឹងគាត់ចាស់មែនទែន គាត់ឈឺ ។

ដានី ៖ គាត់ចាស់ហើយ ។

និតៈ នេះគាត់នេះ ។

ដានី ៖ នៅណាឥលូវ?

និតៈ នៅហួសសាលារៀនបឋម ។ អ្នកជិតខាង« នៅជាប់ផ្ទះខ្ញុំ ខាងជើងផ្ទះខ្ញុំ» ។

ដានី ៖ នៅជាប់ផ្ទះអ៊ំ?

អ្នកជិតខាងៈ ហ្នឹងហើយ ជាប់រំលងដីមួយប្លង់ ។

និតៈ គាត់ទើបមកនៅនេះទេ ។

ដានី ៖ នៅរយៈពេលប៉ុន្មាន?

និតៈ នៅយូរដែលហើយ កាលមុនគាត់នៅក្រចេះ គាត់នៅដូចថាជាប់ពីពួកខ្ញុំទៅ គាត់អត់មាន គាត់មកនៅជាមួយកូនគាត់ ។

ដានី ៖ កូនគាត់នៅនេះ?

និតៈ ចា៎!

ដានី : អ៊ីចឹងគាត់ទៅគ្រប់គ្រងនៅពេទ្យហ្នឹង ឆ្នាំជិតជាង ចុះ ពូជូ នៅហ្នឹងដែរ?

និតៈ ពូជូ នៅហ្នឹងគាត់បច្ចេកទេស ហើយ មីងវីន គាត់គ្រប់គ្រងពីលើទាំងអស់មួយពេទ្យកងពលហ្នឹង ពូជូ ហើយ បងសៀន គាត់បច្ចេកទេស ហើយ មីងវីន គាត់អត់ចេះអីទេ ។

ដានី : អត់ចេះអីទេ?

និតៈ ចា៎! គាត់គ្រាន់តែគ្រប់គ្រងកំលាំងនៅហ្នឹង ប៉ុន្តែទៅដល់ហ្នឹងកំលាំងច្រើនណាស់ តាំងពីអ្នករបួសរាប់រយ ។

ដានី : វីន ហ្នឹងគាត់ត្រូវម៉េចនឹង តាអាន?

និតៈ ប្អូន ពូអាន បង្កើត ។ សំដីអ្នកជិតខាង« ដំបូងមកជាមួយ តាអាន ប្ដីគាត់ ហើយមានគេទៅនៅមណ្ឌលគិរីគេលក់ដីហ្នឹង គាត់ទិញយកទៅ» ។

ដានី : មីងកាលទៅនៅមណ្ឌលគិរីធ្វើពេទ្យ ធ្វើអីខ្លះទៅ?

និតៈ ព្យាបាលជំងឺ ។

ដានី : ហើយម៉េចទៀត?

និតៈ ហើយខ្ញុំដើរព្យាបាលតាមកងពល ។

ដានី : ភាគច្រើនជំងឺអីខ្លះទៅកាលហ្នឹង?

និតៈ ភាគច្រើនគឺគ្រុនចាញ់តែម្ដង ហើយរបួសខ្លះ កាលហ្នឹងរបួសវៃតាមព្រំដែន ។

ដានី : ពូគាត់ត្រូវរបួសឆ្នាំណា?

និតៈ ឆ្នាំ៧៨ ហើយខ្ញុំមិនដែលដឹងគាត់ទេ ។

ដានី : អត់ដែលដឹងទេ?

និតៈ ខ្ញុំកាលគាត់របួស ខ្ញុំទៅប្រចាំនៅព្រំដែន គេយកពេទ្យទៅប្រចាំព្រំដែនមួយក្រុម គេយកខ្ញុំទៅដាក់ព្រំដែន ។

ដានី : ហើយ ០៦ គាត់ទៅមណ្ឌលគិរីឆ្នាំណា?

និតៈ អត់បានចាំឆ្នាំ ។

ដានី : តែមុន ០៦ ទៅ មានពីណាគេប្រធាន?

និតៈ តាឈិន ។

ដានី : មីងស្គាល់គាត់ដែរ?

និតៈ ខ្ញុំអត់ស្គាល់ទេ កាលមុនបង០៦ទៅ គេដឹកខ្ញុំម៉ាឡានទៅជិតព្រំដែន ពួកពេទ្យកងពល ខ្ញុំមិន ស្មានថាគេដឹកហ្នឹង គេបញ្ជូឲ្យយកទៅវៃចោលទេ អត់ដឹងទេ

ដល់តែកុងឡានអាណិតពួកខ្ញុំ គេដឹកវៀង ដល់បង០៦ទៅទាន់បានយកទៅវិញ ដល់គេយកខ្ញុំទៅដាក់នឹងជិតទល់ដែនយួន ហ្នឹងបានបង០៦ទៅ បង០៦បញ្ជាយកពួកខ្ញុំមកវិញ ខ្ញុំអត់ដឹងគេយកខ្ញុំទៅវៃចោលទេ គេបញ្ជា ប៉ុន្តែតែកុងថាហ្នឹងហើយសំណាងបាន គេចាំនៅកន្លែងជ្រោះហ្នឹងស្រេចហើយ ២ឡានពួកខ្ញុំ បានបង០៦ទេគាត់ទៅទាន់ គាត់ថាអែង បានអញមកទាន់ទេកុំអីងាប់បាត់ ។

ដានី ៈ គាត់ថាអីចឹងដែរ?

និតៈ ចា៎! ខ្ញុំ ហើយនិងបង០៦ ដូច តាឈិន ខ្ញុំមិនដែលស្គាល់ទេ បើបង០៦ បង៧៩ ហ្នឹងខ្ញុំ ខស្សរាហ៍ដើរព្យាបាលគាត់តាមកងពល ។

ដានី ៈ បង៧៩ឈ្មោះអី?

និតៈ បងនួន ហើយតាសឿន គេហៅតាសឿន មុខដូហ្នឹងក៏ខ្ញុំខស្សរាហ៍ព្យាបាលគាត់ ។

ដានី ៈ ចុះមីងវីន មីងស្គាល់គាត់ច្បាស់ដែរ?

និតៈ ស្គាល់ ប៉ុន្តែគាត់នៅជាមួយខ្ញុំហ្នឹងពេទ្យហ្នឹងហើយ កាលនៅតូចៗខ្ញុំដែលស្គាល់ ។

ដានី ៈ កាលនៅពេទ្យគាត់ម៉េចដែរ កាច ឬស្លូត?

និតៈ គាត់មិនកាចប៉ុន្មានទេ តែកាលណាគាត់បញ្ជាខ្ញុំឲ្យខ្ញុំយកគ្រួសារហ្នឹង មិនមែនយកគាត់នេះទេ ឲ្យយកអត់ខ្លាច ឲ្យខ្ញុំយកអ្នកផ្សេង ខ្ញុំថាខ្ញុំមិនយកទេ ចុះចេញហើយ គាត់ថាខ្លាំង ។

ដានី ៈ គាត់ថាម៉េច?

និតៈ គាត់ថាអ្នកខ្លាំង ខ្ញុំថាអត់យកទេបើខ្ញុំអត់ស្រឡាញ់ គាត់អត់ហ៊ានដែរ គាត់ឃើញខ្ញុំ ។

ដានី ៈ ឆ្នាំណាហ្នឹង?

និតៈ កាលហ្នឹងឆ្នាំ៧៨ហ្នឹង គាត់ដាច់ជើងហើយតែខ្ញុំអត់ឃើញគាត់ហ្នឹងទេ តែគ្រួសារខ្ញុំនេះទំរាំ បាន១០ឆ្នាំ បង០៦ឲ្យយកតាំងពីឆ្នាំ៧៩ អាហ្នឹងរត់ហើយគេឲ្យខ្ញុំការប៉ុន្តែខ្ញុំអត់ការខ្ញុំនឹក ឃើញសង្រ្គាមខ្លាចពេលយើងរត់ទៅ យើងមានកូនមានចៅ ខ្ញុំមើលឃើញអ្នកមានមុនៗគេ ប្រវ៉ាត់ចោលកូនខ្ញុំអត់យកគាត់ទេ ១០ឆ្នាំបានគាត់ ខ្ញុំចាំទាល់តែ១០ឆ្នាំ ឡើងមកភ្នំ ដងរែកនេះគេការ ។

ដានី ៈ ទាល់តែ១០ឆ្នាំបានការ?

និតៈ ចា៎!

ដានី ៈ អីចឹងមីងជួប តាអាន ជួបពេលណា?

និត: ខ្ញុំមកនៅដងវែកហើយ ខ្ញុំអត់ដែលស្គាល់ទេ ពូអាន ខ្ញុំមកនៅដងវែកហើយបានជួបគាត់ ។

ដានី : ជួបគាត់នៅដងវែកនៅម្តុំណា?

និត: នៅភូមិប្រជាជនហ្នឹងគេដាក់គាត់ធ្វើប្រធានភូមិប្រជាជន ។

ដានី : ដាក់គាត់ធ្វើប្រធានភូមិប្រជាជននៅណាទៅ?

និត: នៅហ្នឹងមុំពាហ្នឹងឯង ។

ដានី : មុំពាខាងជិតទន្លេល្ពៅ?

និត: ចា៎! ហ្នឹងឯងគាត់នៅមួយជំនៀរហ្នឹង ខ្ញុំទៅឃ្លាំង អាហ្នឹងចេញពីពេទ្យហើយគេបញ្ជូនមក ដងវែក ។

ដានី : ចុះមីងរីន គាត់មកនៅហ្នឹងដែរ?

និត: គាត់អត់ទេ ។

ដានី : គាត់ទៅនៅណា?

និត: មិនដឹងគាត់ទៅនៅណាខ្ញុំអត់ដឹងតាំងពីហ្នឹងមក អត់ដែលដឹង ខ្ញុំបែកគាត់ពីពេទ្យមក ខ្ញុំមក នៅជាមួយទ័ពម្តងកាលហ្នឹង ចេញពីពេទ្យគេបំបែកពេទ្យចេញអស់ហើយ កាលហ្នឹងរត់យួន ៧៩នោះ គេបំបែកពេទ្យចេញអស់ ហើយមកនៅជាមួយ តានីម ម្តង តានីម ហ្នឹងទ័ព ហើយដល់នៅជាមួយ តានីម ហ្នឹងហើយគេបញ្ជូនមកដងវែកហ្នឹង ខ្ញុំមកនៅឃ្លាំងនៅកងដឹក ជញ្ជូនតែម្តង ។

ដានី : នៅជាមួយ តាអាន ដែរអត់?

និត: អត់ទេ នៅឃ្លាំងតែម្តង នៅកងដឹកជញ្ជូនភូមិបេងហ្នឹង ហើយខ្ញុំមកនៅហ្នឹង នៅជាមួយ បងខុម ។

ដានី : ខុម ណា?

និត: បងខុម នៅផ្លូវបំបែក ហ្នឹងប្រធានកង ។

ដានី : អីចឹងមីងនៅហ្នឹងរហូតដល់ឆ្នាំណាបាន?

និត: នៅហ្នឹងរហូត ខ្ញុំមកនៅឃ្លាំង គេឲ្យនៅឃ្លាំងសំងាត់ ដល់ខ្ញុំរៀបជាមួយគាត់ រៀបហើយ គេបញ្ជូនទៅអន្លង់វែង ចុះពីអន្លង់វែងឡើងមកនៅតែម្ត ។

ដានី : បញ្ជូនទៅអន្លង់វែង បញ្ជូនមកទាំងអស់គ្នា?

និត: ចា៎! ទាំងអស់ ។

ដានី : តាអាន ក៏គាត់ចុះមកអន្លង់វែងដែរ?

និតៈ	ពូអាន ចុះទៅអន្លង់វែងដែរ តែគាត់ទៅខាងភាគកណ្ដាល ប៉ុន្តែគាត់ទើបមកនៅនេះទេ គាត់ អត់បានមកជាមួយខ្ញុំទេ ពួកខ្ញុំនៅក្រសួងមន្ទីរជាមួយ តាខៀវ ហើយ តាអាន ទើបតែ មកដែរទេ ។

ដានី :	តាអាន គាត់នៅអន្លង់វែង រហូតដល់ឆ្នាំណាបានមក?

និតៈ	អត់ដឹងដែរ មិនដឹងគាត់នៅដល់ឆ្នាំណា ប៉ុន្តែគាត់ទើបតែបែកពីគេមក គាត់មកនៅជាមួយ ពួកខ្ញុំ ខ្ញុំពួកមន្ទីរ តាខៀវ គេបញ្ជូនមកមុន គេឲ្យទៅនៅជាមួយ តាម៉ុក ប៉ុន្តែ តាខៀវ គាត់ថាអត់ចោលទេ គាត់យកពួកខ្ញុំមក កុំអីពួកខ្ញុំនៅជាមួយ តាម៉ុក ទៅនៅអន្លង់វែង កាលហ្នឹងខ្ញុំឈឺឪខ្ញុំសួរថានៅជាមួយ តាម៉ុក អី ខ្ញុំថាអត់នៅទេខ្លាច តាម៉ុក វៃចោល ខ្ញុំ មកតាម តាខៀវ ខ្ញុំខ្លាច តាម៉ុកៗ កាច ។

ដានី :	ឆ្នាំ៩២ មីងមកនេះមក?

និតៈ	ចា៎!

ដានី :	មីងការឆ្នាំប៉ែតប៉ុន្មាន?

និតៈ	ខ្ញុំភ្លេចហើយ គាត់ប៉ុនចាំ ។

ដានី :	ការហើយមានកូន?

និតៈ	ការហើយនៅរត់លិចកើត មានកូនប៉ុន្តែរាប់ ប៉ុន្តែរត់មិនមែនរត់ដូចកាលពីជំនាន់៧៩ទេ ។

ដានី :	កូនបងមីងឆ្នាំណា មានកូនទី១?

និតៈ	ឆ្នាំប៉ុន្មានទេ ខ្ញុំភេចអស់ហើយខ្ញុំមិនចាំទេ មកនៅអន្លង់វែងបានមានកូនខ្ញុំស្រីមួយ ។

ដានី :	ឆ្នាំកៅ?

និតៈ	ឆ្នាំ៧៨ មិនដឹងមីស្រីហ្នឹង អាមួយរៀនថ្នាក់ទី១២ បាន៩១ ហើយអាមួយតូចកើតមក នៅហ្នឹងតែម្ដង ។

ដានី :	អីចឹងមីងមានកូនតែ៣នាក់ទេ?

និតៈ	៤នាក់ ទាំងអារាប់មួយ ។

ដានី :	មួយ៨៨ ឬ៧៨? ៧៨មីងមិនទាន់ការឯណា?

និតៈ	ឆ្នាំប៉ុន្មានទេ កូនខ្ញុំមីមួយនោះ កើតឆ្នាំរោង ទើប២២ ។

ដានី :	រោង ឆ្នាំ៨៨-៨៩ហើយ ។ មីងបានទៅលេងផ្ទះឆ្នាំណា?

និតៈ	បានទៅលេងឆ្នាំណាទេកាលហ្នឹង ទៅបាន ។

ដានី :	ពូទៅមុន ឬមីងទៅមុន?

និតៈ ឪខ្ញុំទៅមុន គាត់ទៅហើយគាត់ទៅម៉ែខ្ញុំ ទៅរកម៉ែខ្ញុំឃើញហើយបានខ្ញុំទៅក្រោយ ខ្ញុំអត់សូវហ៊ានដើរទេខ្ញុំខ្លាច ។

ដានី ៈ ឲ្យគាត់ទៅរកឲ្យ?

និតៈ គាត់ទៅរកឃើញ គាត់ទៅស្រុកគាត់ផង គាត់មកវិញចូលស្រុកខ្ញុំ ហើយខ្ញុំឥលូវក៏មិនសូវហ៊ានដើរ ខ្ញុំមិនដែលដើរ ។

ដានី ៈ អ៊ីចឹងមីងបានទៅផ្ទះប៉ុន្មានដងដែរអ៊ីចឹង?

និតៈ ទៅ២-៣ដងហើយ ទាល់តែម៉ែខ្ញុំស្លាប់ហ្នឹង ។

ដានី ៈ បងប្អូនមីងគាត់នៅណាឥលូវ?

និតៈ នៅនេះមួយ អាមួយនេះប្អូនខ្ញុំ ។

ដានី ៈ ហ្នឹង?

និតៈ ចា៎!

ដានី ៈ ប្អូនមីងបង្កើត?

និតៈ ចា៎! ហើយនៅស្រុក២ អានេះវាអត់មានស្អី វាអត់មានដីធ្លីក៏មកសុំដីធ្វើ ឲ្យធ្វើខ្លះចែកគ្នាបន្តិចៗ ហើយវាកូនច្រើនផង ។

ដានី ៈ មីងទៅលេងផ្ទះដំបូងបងប្អូនភ្ញាក់ផ្អើលទេ?

និតៈ ចា៎! ហើយខ្ញុំក៏អត់ស្គាល់ចាស់ៗ ។

ដានី ៈ អត់ស្គាល់ទេ?

និតៈ ចា៎! ខ្ញុំអត់ស្គាល់ទេ អត់ស្គាល់ទាំងផ្ទះកន្លែងខ្លួនឯងផង ។

ដានី ៈ អត់ស្គាល់ផ្ទះទៀតនេះ?

និតៈ ទាល់តែគេនាំទៅពីស្រុកមកគេមកយក ទើបខ្ញុំទៅ ព្រោះខ្ញុំចេញមកយូរហើយ កាលនៅតូច ។

ដានី ៈ អ៊ីចឹងដោយសារមីងចេញពីតូច មីងទៅស្រុកមិនសូវបានយូរទេ នឹកផ្ទះនៅនេះ?

និតៈ ចា៎! ខ្ញុំអត់ស្គាល់ម៉ែខ្ញុំ ម៉ែខ្ញុំមករកខ្ញុំហ្នឹង ខ្ញុំអត់ស្គាល់ផងហ្នឹង ។

ដានី ៈ អត់ស្គាល់ម៉ែទៀត?

និតៈ ចា៎! ម៉ែខ្ញុំមកកាលពីមិនទាន់ផ្តាច់ខ្លួននោះ គាត់មករកជាប់គុកនៅថៃឡើងយូរដែរហ្នឹង បានខ្ញុំដឹង ។

ដានី ៈ ពីណាជាប់គុកនៅថៃ?

និតៈ ម៉ែខ្ញុំ គាត់ចូលដីថៃ ។

ដានី ៖ គាត់មករកមីង?

និតៈ ចា៎!

ដានី ៖ រកទៅថៃចាប់?

និតៈ គាត់ចូលដីថៃហើយ ថៃចាប់ដាក់គុក ទាល់តែគេយកមកខ្ញុំដោះអស់ឡើង១ម៉ឺនបាត ។

ដានី ៖ មីងដូចជាមិត្តភក្ត្រអត់ស្គាល់គ្នា ព្រោះមីងចេញពីស្រុកតាំងពីនោះ?

និតៈ អត់ស្គាល់ទេ ទៅដល់គ្មានសល់ទេ ដល់ពេលខ្លះគេស្គាល់ គេសួរទៅ ខ្ញុំថ្នាក់បងថ្លៃខ្ញុំថាអឺ ខ្ញុំអត់ស្គាល់សោះ ។

ដានី ៖ អ៊ីចឹងមីងទៅស្រុកអត់សូវបានយូរទេអ៊ីចឹង?

និតៈ ទេ ទៅយូរដែរ ។

ដានី ៖ ទៅប៉ុន្មានថ្ងៃដែលម្តងៗ?

និតៈ ទៅប្រហែល៨-១០ថ្ងៃខ្ញុំមកវិញ ហើយម្យ៉ាងខ្ញុំប្រញាប់ចម្ការស្រែផង ស្រុកនេះអត់មានពេលទំនេរទេ ។

ដានី ៖ ឥលូវៗនេះមានបានទៅទៀតទេ?

និតៈ ខានទៅ២ឆ្នាំហើយ តាំងពីម៉ែខ្ញុំស្លាប់ ។

ដានី ៖ ពូទៅដុះមុនពី៩៧ មីងទៅដំបូងពីឆ្នាំប៉ុន្មានកាលហ្នឹង?

និតៈ មិនដឹងឆ្នាំប៉ុន្មានទេកាលហ្នឹង ប្អូនខ្ញុំមកយកបានខ្ញុំហ៊ានទៅ ។

ដានី ៖ ម្តាយមីងមករកមីងឆ្នាំណា ដែលគាត់ជាប់?

និតៈ កាលហ្នឹងមិនទាន់ផ្តាច់ខ្លួនទេ គាត់មករក គាត់រកតាមដីថៃនោះ ហើយមកជួប ពូដុះ ។

ដានី ៖ បានជួបមីងទេកាលហ្នឹង?

និតៈ ជួប ពូដុះ ប្រធានមន្ទីរពួកខ្ញុំនៅ គាត់ហៅទៅជួបហើយគាត់សួរថាស្គាល់ម៉ែទេ ខ្ញុំថាអត់ស្គាល់ មិនដឹងមុខម៉ែខ្ញុំម៉េចផង ដល់ពេលម៉ែខ្ញុំភ័យដែរហ្នឹងខ្លាចកូនអត់ស្គាល់ម៉ែ ដល់យកមកយូរៗខ្ញុំចេះមើលមុខទៅ ម៉ែខ្ញុំ ។

ដានី ៖ មីងកាលពីមីងអត់ទាន់សមាហរកកម្ម ហើយក្រោយសមាហរកម្ម មីងគិតថាមួយណាស្រួលនៅជាង?

និតៈ ឥលូវនេះទេវាស្រួលជាង មុនវានៅតឹងតែងអារឿងបាញ់គ្នា ហើយរកស៊ីក៏លំបាកដែរ ។

ដានី ៖ មីងអត់ចង់ទៅនៅស្រុកកំណើតវិញទេ?

និត: អត់ទេ ស្រុកខ្ញុំរកស៊ីមិនបាន។ គ្មានដីធ្លីអីទេ ម៉ែឪគេយកដីចែកគ្នាអស់ហើយ កាលជំនាន់ខ្មែរក្រហមហ្នឹងគេចែកគ្នាអស់ហើយដី។

ដានី : នៅនេះយើងមានដីមានធ្លី មានផ្ទះ។

និត: មានផ្ទះខ្លួនឯង គេកាប់ដីបាន។

ដានី : មីងគិតថានៅនេះរហូតហើយ?

និត: ចា៎! ខ្ញុំអត់ទៅ។

ដានី : មីងដែលទៅលេងស្រុកពូនៅខ្ទបតាផ្លួន?

និត: ទៅម្តង។ ទៅធ្វើបុណ្យលើកខ្មោចឪពុកគាត់ហ្នឹង។

ដានី : សំនួរចុងក្រោយមួយដូចខ្ញុំសួរពូដែរ មីងដូចថាឥលូវហ្នឹងគេបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូចជា កាំង ហ្គេកអ៊ាវ ហៅឌុច មីងស្គាល់គាត់ទេ?

និត: ខ្ញុំអត់ស្គាល់។

ដានី : លឺទេ ឈ្មោះ?

និត: ឃើញតែមុខ តា នួន ជា ខ្ញុំឃើញ តែ តាឌុច ខ្ញុំមិនដែលស្គាល់ទេ។

ដានី : តា នួន ជា មីងស្គាល់ទេ?

និត: ឃើញមុខ។

ដានី : តា អៀង សារី?

និត: តា អៀង សារី ខ្ញុំដែលឃើញ។

ដានី : តា អៀង សារី ប្រពន្ធគាត់ អៀង ធីរិទ្ធ?

និត: ចា៎!

ដានី : ខៀវ សំផន?

និត: អ៊ំ ខៀវ សំផន អត់ឃើញគាត់ទេ ឃើញរូបថត តែប្រពន្ធតា អៀង សារី ខ្ញុំដែលឃើញ។

ដានី : ដែលជួបគាត់ទេកាលពីសម័យ៣ឆ្នាំ ហើយក្រោយៗអីមក?

និត: អត់ដែលជួបទេ គ្រាន់តែឃើញរូបថតតែបើ តា អៀង សារី ខ្ញុំដែលឃើញ ខ្ញុំទៅធ្វើការកន្លែងតា។

ដានី : ចុះគេកាត់ទោសគាត់អីចឹង មីងគិតថាគេកាត់ហ្នឹងត្រឹមត្រូវដែរ ឬក៏យ៉ាងម៉េចតាមចិត្តមីង?

និតៈ អត់មានថាអីទេច្បាប់ អាហ្នឹងគេធ្វើទៅតាមច្បាប់ ទោះបីខ្ញុំធ្លាប់ឃើញគាត់ក៏ខ្ញុំអត់មានធ្វើទៅតាមច្បាប់បាន ព្រោះច្បាប់គេធ្វើទៅហើយ ។

ដានី ៖ អ៊ីចឹងខ្ញុំអស់សំនួរអីសួរនាំមីងទៀតហើយ អ៊ីចឹងមីងមានអីចង់បន្ថែមអ៊ីដែលខ្ញុំមិនទាន់សួរនាំទេ ។

និតៈ អត់មានទេ ។

ដានី ៖ អ៊ីចឹងខ្ញុំអរគុណមីងច្រើន ដែលចំនាយពេលសំណេះសំណាលជាមួយទាក់ទងនឹងជីវិតរបស់មីង ឥលូវថ្ងៃណាស់ទៅហើយពូគាត់ប្រហែលជាហេវបាយ ។

**ចប់**